**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ០០៧៧ សប្រក

ថ្ងៃសុក្រ ១៤កើត ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19

ក្រសួងទេសចរណ៍ សូមជម្រាបជូនដល់បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ប្រតិបត្តិករទេសចរណ៍ សហព័ន្ធទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីធានាដល់បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរទាំងអស់ឲ្យមានសមត្ថភាព ជំនាញ និងគុណវុឌ្ឍិក្នុងការផ្តល់សេវាកម្មជូនភ្ញៀវប្រកបដោយគុណភាព សុវត្ថិភាព និងអនាម័យខ្ពស់ឆ្លើយតបនឹងការរីករាលដាលជំងឺឆ្លង COVID-19 ក្រសួងទេសចរណ៍តម្រូវឱ្យបុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរទាំងអស់ត្រូវមានការបណ្តុះបណ្តាល និង/ឬ វាយតម្លៃសមត្ថភាពផ្អែកលើកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 ដែលក្រសួងទេសចរណ៍បានដាក់ចេញ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីប្រកាសព័ត៌មាននេះ)។ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពនេះជាការចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺឆ្លង COVID-19 នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ប្រតិបត្តិករទេសចរណ៍ សហព័ន្ធទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការដោយស្មារតីទទួលខុសត្រូវខ្ពស់ ជាពិសេសចំពោះបុគ្គលិកត្រូវចូលរួមចុះឈ្មោះសិក្សាក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 នេះ និងចំពោះប្រតិបត្តិករទេសចរណ៍ សហព័ន្ធទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ ត្រូវធ្វើការណែនាំ និងបញ្ជូនបុគ្គលិក និយោជិតរបស់ខ្លួនធ្វើការចុះឈ្មោះសិក្សា និង/ឬ ស្នើសុំវាយតម្លៃសមត្ថភាពអនឡាញ ផ្អែកលើសមត្ថភាពតម្រូវដែលមាននៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពនេះ តាមរយៈអាសយដ្ឋានគេហទំព័រ https://www.tptd.org ឬតាមរយៈស្កេន QR Code ខាងក្រោម។

សម្រាប់ព័ត៌មានបន្ថែមផ្សេងៗទៀត សូមធ្វើការទាក់ទងដោយផ្ទាល់មកកាន់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ឬ តាមរយៈលេខទូរស័ព្ទ: 012 278 552 ឬ 078 899 919 **រៀងរាល់ម៉ោងធ្វើការ។**

**ក្រសួងទេសចរណ៍**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ២០៤ [illegible]

ថ្ងៃ សុក្រ ១៥ កើត ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០២០

# សេចក្ដីជូនដំណឹង

## ស្ដីពី

## កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19

ដើម្បីចូលរួមជំរុញអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 ដែលបានដាក់ចេញសំដៅធានាដល់បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរទាំងអស់ឲ្យមានសមត្ថភាព ជំនាញ និងគុណវុឌ្ឍិក្នុងការផ្ដល់សេវាកម្មជូនភ្ញៀវប្រកបដោយគុណភាព សុវត្ថិភាព និងអនាម័យខ្ពស់ ក្រសួងទេសចរណ៍ សូមជូនដំណឹងដល់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ប្រតិបត្តិករទេសចរណ៍ សហព័ន្ធទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងសាធារណជនទាំងអស់ ឲ្យបានជ្រាបថា ក្រសួងទេសចរណ៍នឹងរៀបចំវគ្គបណ្ដុះបណ្ដាល និងវាយតម្លៃសមត្ថភាពដល់បុគ្គលិក និយោជិតបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ ដោយចាប់ផ្ដើម **ពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០** តាមកម្មវិធី លក្ខខណ្ឌ និងខ្លឹមសារលម្អិតដូចខាងក្រោម៖

I. **អំពីវគ្គបណ្ដុះបណ្ដាល**

- វគ្គបណ្ដុះបណ្ដាលនឹងធ្វើឡើងតាមប្រព័ន្ធអនឡាញ តាមអាសយដ្ឋាន https://www.tptd.org ។
- វគ្គបណ្ដុះបណ្ដាលនឹងរៀបចំឡើងតាមសមត្ថភាព និងកាលបរិច្ឆេទដូចខាងក្រោម៖

១. វគ្គសិក្សាសមត្ថភាព៖ **ចំណេះដឹងអំពីធាតុការការពារជាមូលដ្ឋាន និងគោលការណ៍ណែនាំស្ដីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគសម្រាប់ឧស្សាហកម្មទេសចរណ៍**

❖ សិក្សារៀងរាល់ថ្ងៃច័ន្ទ **ដោយមាន ២វេន (១វេន រយៈពេល ០២ ម៉ោង)**

- **វេនព្រឹក៖** **០៩:០០-១១:០០**
- **វេនរសៀល៖** **១៥:០០-១៧:០០**

២. វគ្គសិក្សាសមត្ថភាព៖ **អនុវត្តការងារស្របតាមនីតិវិធីអនាម័យនៅកន្លែងការងារ**

❖ សិក្សារៀងរាល់ថ្ងៃអង្គារ **ដោយមាន ២វេន (១វេន រយៈពេល ០២ ម៉ោង)**

- **វេនព្រឹក៖** **០៩:០០-១១:០០**
- **វេនរសៀល៖** **១៥:០០-១៧:០០**

៣. វគ្គសិក្សាសមត្ថភាព៖ **អនុវត្តនីតិវិធីសុខភាព និងសុវត្ថិភាពក្នុងអាជីព**

❖ សិក្សារៀងរាល់ថ្ងៃពុធ **ដោយមាន ២វេន (១វេន រយៈពេល ០២ ម៉ោង)**

- **វេនព្រឹក៖** **០៩:០០-១១:០០**

[illegible] E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- **វេនរសៀល៖** **១៥:០០-១៧:០០**

៤. វគ្គសិក្សាសមត្ថភាព៖ **សម្អាតបរិវេណ និងឧបករណ៍**

❖ សិក្សារៀងរាល់ថ្ងៃព្រហស្បតិ៍ **ដោយមាន ២វេន (១វេន រយៈពេល ០២ ម៉ោង)**

- **វេនព្រឹក៖** **០៩:០០-១១:០០**
- **វេនរសៀល៖** **១៥:០០-១៧:០០**

៥. វគ្គសិក្សាសមត្ថភាព៖ **ក្រមប្រតិបត្តិ និងវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មទេសចរណ៍**

❖ សិក្សារៀងរាល់ថ្ងៃសុក្រ **ដោយមាន ២វេន (១វេន រយៈពេល ០២ ម៉ោង)**

- **វេនព្រឹក៖** **០៩:០០-១១:០០**
- **វេនរសៀល៖** **១៥:០០-១៧:០០**

## II. ការវាយតម្លៃសមត្ថភាពបញ្ចប់វគ្គ

- សិក្ខាកាមដែលបានសិក្សាក្នុងវគ្គសិក្សាសមត្ថភាពនីមួយៗ តម្រូវឱ្យឆ្លងកាត់ការប្រឡងតេស្តសមត្ថភាពបញ្ចប់វគ្គតាមរយៈអនឡាញ រយៈពេល **៤៥ នាទី** (សំណួរជ្រើស **៣០ នាទី** និងសំណួរសរសេរ **១៥ នាទី**)
- សិក្ខាកាមដែលបានសិក្សាក្នុងវគ្គសិក្សាសមត្ថភាពនីមួយៗ មានរយៈពេល **០១ សប្តាហ៍** គិតចាប់ពីថ្ងៃសិក្សាលើសមត្ថភាពនីមួយៗ ដើម្បីធ្វើ**ស្វ័យប្រឡងតេស្តសមត្ថភាពរបស់ខ្លួនតាមអនឡាញ**
- សិក្ខាកាមដែលបានប្រឡងតេស្តសមត្ថភាពជាប់ នឹងទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដែលបានសិក្សា ពីក្រសួងទេសចរណ៍
- កាលបរិច្ឆេទប្រឡងតេស្តសមត្ថភាពបញ្ចប់វគ្គ នឹងបើកឱ្យមានការប្រឡង ចាប់ផ្តើមពីថ្ងៃទី**២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។**

## III. នីតិវិធីចុះឈ្មោះ

បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរទាំងអស់ អាចធ្វើការចុះឈ្មោះសិក្សា និងបុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដែលមានចំណេះដឹង និងសមត្ថភាពដែលពាក់ព័ន្ធសមត្ថភាពតម្រូវនៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ ឆ្លើយតបនឹងជំងឺឆ្លង COVID-19 អាចធ្វើការចុះឈ្មោះស្នើសុំវាយតម្លៃសមត្ថភាពរបស់ខ្លួន តាមរយៈអាសយដ្ឋាន គេហទំព័រ https://www.tptd.org ឬ តាមរយៈស្កេន QR Code ខាងក្រោម៖

## IV. **លក្ខខណ្ឌសម្រាប់ទទួលស្គាល់សមត្ថភាព**

ដើម្បីទទួលបាននូវការទទួលស្គាល់សមត្ថភាពជាបុគ្គលិកបម្រើការងារដែលមានសមត្ថភាព និងគុណវុឌ្ឍិក្នុងការផ្តល់សេវាកម្មជូនភ្ញៀវ ប្រកបដោយគុណភាព ភាពស្អាត និងអនាម័យ ស្របតាមស្តង់ដា បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរទាំងអស់ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល និង/ឬ ការវាយតម្លៃសមត្ថភាពលើសមត្ថភាពយ៉ាងហោច ០៣ សមត្ថភាព ដែលមានតម្រូវនៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 (ដែលមានភ្ជាប់ជាមួយសេចក្តីជូនដំណឹងនេះ)។

**សម្គាល់៖**

- សម្រាប់បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដែលមានចំណេះដឹង និងសមត្ថភាព ដែលពាក់ព័ន្ធសមត្ថភាពតម្រូវនៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 រួចហើយ អាចធ្វើការស្នើសុំការវាយតម្លៃសមត្ថភាពអនឡាញតែម្តង ដោយមិនចាំបាច់ចូលរៀនក្នុងវគ្គសិក្សាសមត្ថភាពនោះឡើយ។
- បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរចាំបាច់ត្រូវធ្វើការចុះឈ្មោះសិក្សានៅក្នុងវគ្គនីមួយៗ ដើម្បីចូលរៀនក្នុងវគ្គសិក្សាសមត្ថភាពដែលខ្លួនចង់សិក្សា។

ចំពោះព័ត៌មានបន្ថែមផ្សេងៗទៀត សូមធ្វើការទាក់ទងដោយផ្ទាល់នៅនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ឬតាមរយៈលេខទូរស័ព្ទ: 012 278 552 ឬ 078 899 919 **រៀងរាល់ម៉ោងធ្វើការ។**

**ក្រសួងទេសចរណ៍**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

# កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍

# ឆ្លើយតបនឹងជំងឺឆ្លង COVID-19



២០២០

# មាតិកា


I. សេចក្តីផ្តើម ១

II. គោលបំណង ២

III. កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 ២

IV. ការទទួលស្គាល់សមត្ថភាព និងគំរូវិញ្ញាបនបត្រទទួលស្គាល់ ៣

៤.១ ការទទួលស្គាល់សមត្ថភាព ៣

៤.២ គំរូវិញ្ញាបនបត្រទទួលស្គាល់សមត្ថភាព ៣

V. យន្តការសម្រាប់ដាក់ឱ្យដំណើរការអនុវត្តកម្មវិធី ៤

## I. **សេចក្តីផ្តើម**

ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យទេសចរណ៍មានការរីកចម្រើនគួរឱ្យកត់សម្គាល់នារយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ។

ទន្ទឹមនឹងវិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាវិស័យអាទិភាពដើរតួនាទីជា **"មាសបៃតង"** រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការបង្កើត និងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋ ដោយផ្ទាល់ និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ជំរុញកំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ពិសេសចូលរួមដល់ការឆ្លើយតបនឹងបំរែបំរួលអាកាសធាតុ ក្រសួងទេសចរណ៍ បាន និងកំពុងយកចិត្តទុកដាក់ខ្ពស់លើការលើកកម្ពស់គុណភាពសេវាកម្មតាមរយៈការជំរុញអភិវឌ្ឍសមត្ថភាព និងបណ្តុះបណ្តាលជំនាញថ្មី និងបន្ថែម (Re-Skilling and Up-Skilling) ដល់អ្នកបម្រើការក្នុងវិស័យទេសចរណ៍ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារទេសចរណ៍ទាំងបរិមាណ និងគុណភាព។

ជាពិសេសដើម្បីចូលរួមបំពេញតម្រូវការអភិវឌ្ឍន៍សមត្ថភាព និងជំនាញសម្រាប់អ្នកជំនាញទេសចរណ៍ដែលបាននិងកំពុងបម្រើការក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ គ្រប់កាលៈទេសៈ ទាំងក្នុងស្ថានភាពវិវត្តន៍នៃសេដ្ឋកិច្ច សង្គម និងក្នុងស្ថានភាពប្រឈមផ្សេងៗរួមទាំងវិបត្តិនៃការរីករាលដាលជម្ងឺឆ្លងផ្សេងៗ ជាពិសេសជំងឺឆ្លង COVID-19 ក្រសួងទេសចរណ៍ បានមើលឃើញពីសារៈសំខាន់នៃការប្រែក្លាយស្ថានភាពទាំងអស់ជាកាលានុវត្តភាពក្នុងការជំរុញបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព ជំនាញបន្ថែមដល់អ្នកជំនាញទេសចរណ៍ឱ្យមានសមត្ថភាពពិសេសក្នុងការផ្តល់សេវាដល់ភ្ញៀវទេសចរប្រកបដោយគុណភាព សុវត្ថិភាព និងអនាម័យ តាមរយៈការដាក់ចេញ **កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លងCOVID-19**។

**កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 នេះ ត្រូវបានរៀបចំឡើងសម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃ និងបណ្តុះបណ្តាលដល់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងធ្វើដំណើរទាំងអស់ ឱ្យមានសមត្ថភាព ជំនាញ គុណវុឌ្ឍិ ព្រមទាំងមានចំណេះដឹងស៊ីជម្រៅលើការរក្សាភាពស្អាត និងអនាម័យនៅកន្លែងការងារ និងសម្ភារៈប្រើប្រាស់សម្រាប់ការផ្តល់សេវាកម្ម ព្រមទាំងការប្រតិបត្តិផ្តល់សេវាកម្មប្រកបដោយសុវត្ថិភាពដល់ភ្ញៀវ។**

## II. គោលបំណង

*កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19* ត្រូវបានដាក់ចេញក្នុងគោលបំណង ធានាដល់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងធ្វើដំណើរ មានសមត្ថភាព ជំនាញ និងគុណវុឌ្ឍិក្នុងការផ្តល់សេវាកម្មជូនភ្ញៀវប្រកបដោយគុណភាព សុវត្ថិភាព និងអនាម័យខ្ពស់ ឆ្លើយតបវិបត្តិនៃការរីករាលដាលជំងឺឆ្លងCOVID-19។

## III. កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លងCOVID-19 មានឯកតាសមត្ថភាពចម្បង ចំនួន ០៥ ដែលតម្រូវឱ្យមានសម្រាប់អ្នកបម្រើការងារក្នុងអាជីវកម្ម សេវាកម្មទេសចរណ៍ទាំង ១០ រួមមាន៖ សេវាកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ សេវាកម្មរមណីយដ្ឋានទេសចរណ៍ សេវាកម្មមណ្ឌលកំសាន្តមនុស្សពេញវ័យ សេវាកម្មម៉ាស្សាសុខភាព និងស្ប៉ា សេវាកម្មដឹកជញ្ជូនទេសចរណ៍តាមទឹក និងផ្លូវគោក សេវាកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ សេវាកម្មកីឡាទេសចរណ៍ សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ សេវាកម្មអ្នកបកប្រែបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ដូចមានខាងក្រោម៖

| កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 | | |
|---|---|---|
| សមត្ថភាពតម្រូវសម្រាប់អ្នកបម្រើការងារក្នុងអាជីវកម្មសេវាកម្មទេសចរណ៍ទាំង ១០ | | |
| **អាជីវកម្ម/សេវាកម្ម** | **លេខសម្គាល់** | **ឯកតាសមត្ថភាព** |
| គ្រប់អាជីវកម្មសេវាកម្មទាំង ១០ ក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងធ្វើដំណើរ | ១ | ចំណេះដឹងអំពីវិធានការការពារជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគសម្រាប់ឧស្សាហកម្មទេសចរណ៍ |
| | ២ | អនុវត្តការងារស្របតាមនីតិវិធីអនាម័យនៅកន្លែងការងារ |
| | ៣ | អនុវត្តនីតិវិធីសុខភាព និងសុវត្ថិភាពក្នុងអាជីព |
| | ៤ | សម្អាតបរិវេណ និងឧបករណ៍ |
| | ៥ | ក្រមប្រតិបត្តិ និងវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មទេសចរណ៍ |

## IV. ការទទួលស្គាល់សមត្ថភាព និងគំរូវិញ្ញាបនបត្រទទួលស្គាល់

### ៤.១ ការទទួលស្គាល់សមត្ថភាព

ដើម្បីធានាឱ្យអ្នកបម្រើការងារក្នុងអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់មានសមត្ថភាព ចំណេះដឹង និងជំនាញក្នុងការផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយគុណភាព សុវត្ថិភាព ភាពស្អាត និងអនាម័យ ឆ្លើយតបនឹងវិបត្តិនៃការរីករាលដាលជំងឺឆ្លង អ្នកបម្រើការងារក្នុងអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ចាំបាច់ ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព ដោយផ្អែកលើឯកតាសមត្ថភាពចំបង ដែលតម្រូវនៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍នេះ យ៉ាងតិច **០៣ ឯកតាសមត្ថភាព** ដើម្បីបញ្ជាក់ការទទួលស្គាល់សមត្ថភាពរបស់អ្នកបម្រើការសម្រាប់ឧស្សាហកម្មទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លងនេះ។

ដើម្បីជាការទទួលស្គាល់សមត្ថភាព ក្រសួងទេសចរណ៍ នឹងបញ្ជាក់វិញ្ញាបនបត្រសមត្ថភាពជូនអ្នកដែលឆ្លងកាត់ការបណ្តុះបណ្តាល និងអ្នកដែលឆ្លងកាត់ការវាយតម្លៃសមត្ថភាពផ្អែកលើឯកតាសមត្ថភាពតម្រូវនៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍នេះ។

### ៤.២ គំរូវិញ្ញាបនបត្រទទួលស្គាល់សមត្ថភាព

វិញ្ញាបនបត្រទទួលស្គាល់សមត្ថភាព ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

**<u>គំរូវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលសមត្ថភាព</u>**



## គំរូវិញ្ញាបនបត្របញ្ជាក់ការវាយតម្លៃសមត្ថភាព




### V. យន្តការសម្រាប់ដាក់ឱ្យដំណើរការអនុវត្តកម្មវិធី

ការប្រើប្រាស់ **គោលការណ៍កាតព្វកិច្ច** ជាយន្តការក្នុងការដាក់ឱ្យអនុវត្តតាមកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19 ពោលគឺមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ត្រូវធានាឱ្យ បានថា អ្នកបម្រើការងារនៅក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួនត្រូវឆ្លងកាត់ការបណ្តុះបណ្តាល និង ឬ វាយតម្លៃសមត្ថភាពផ្អែកលើឯកតាសមត្ថភាពមាននៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍នេះ តាមរយៈការបើកវគ្គបណ្តុះបណ្តាលសមត្ថភាព ក្រោមការសហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅនឹងកន្លែងផ្ទាល់ (In house training) ឬ ណែនាំផល់បុគ្គលិកដើម្បីចុះឈ្មោះសិក្សាតាមប្រព័ន្ធអនឡាញ E-Learning របស់ក្រសួងទេសចរណ៍តាមរយៈ https://www.tptd.org។ មូលដ្ឋានអាជីវកម្មទេសចរណ៍ក៏អាចបញ្ជូនបុគ្គលិករបស់ខ្លួន ដើម្បីទទួលការវាយតម្លៃសមត្ថភាព ពីនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ឬមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ក្នុងករណី បុគ្គលិករបស់ខ្លួនមានចំណេះដឹង បទពិសោធន៍ និងធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលលើសមត្ថភាពដែលតម្រូវនៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍នេះរួចហើយ។

ជាយន្តការស្ថាប័នសម្រាប់តាមដាន និងជំរុញអនុវត្តកម្មវិធីនេះ នាយកដ្ឋានចំណុះឱ្យក្រសួងទេសចរណ៍ ដែលទទួលបន្ទុកលើការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍នីមួយៗ អាចចូលរួមត្រួតពិនិត្យលើការបណ្តុះបណ្តាលសមត្ថភាពរបស់បុគ្គលិកនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍នីមួយៗ មុនសម្រេចបន្ត ឬផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍ក្នុងស្ថានភាពប្រឈមនឹងជំងឺឆ្លងនេះ។ ដោយឡែក នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សហការជាមួយស្ថាប័នពាក់ព័ន្ធទាំងផ្នែករដ្ឋ និងឯកជន និងប្រតិបត្តិករទេសចរណ៍ ជំរុញការវាយតម្លៃសមត្ថភាព និងផ្តល់ការបណ្តុះបណ្តាលទាំងតាមរយៈ E-Learning និង In house training និងតាមទម្រង់ផ្សេងៗទៀត។

# កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងជំងឺឆ្លង COVID-19

## សម្រាប់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ



**វគ្គសិក្សាចាប់ផ្តើមពី**

**ថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០**

បុគ្គលិក-និយោជិតបម្រើការងារតាមអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់អាចធ្វើការចុះឈ្មោះតាមរយៈប្រព័ន្ធអនឡាញ

វគ្គបណ្តុះបណ្តាលនឹងធ្វើឡើងតាមប្រព័ន្ធអនឡាញ តាមអាសយដ្ឋាន https://www.tptd.org

វគ្គបណ្តុះបណ្តាលនឹងរៀបចំឡើងតាមសមត្ថភាព និងកាលបរិច្ឆេទដូចខាងក្រោម៖

១. វគ្គសិក្សាសមត្ថភាព៖ ចំណេះដឹងអំពីវិធានការការពារជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគសម្រាប់ឧស្សាហកម្មទេសចរណ៍

(សិក្សារៀងរាល់ថ្ងៃច័ន្ទ ដោយមាន ២វេន ១វេន រយៈពេល ០២ ម៉ោង)

វេនព្រឹក៖ ០៩:០០-១១:០០

វេនរសៀល៖ ១៥:០០-១៧:០០

២. វគ្គសិក្សាសមត្ថភាព៖ អនុវត្តការងារស្របតាមនីតិវិធីអនាម័យនៅកន្លែងការងារ

(សិក្សារៀងរាល់ថ្ងៃអង្គារ ដោយមាន ២វេន ១វេន រយៈពេល ០២ ម៉ោង)

វេនព្រឹក៖ ០៩:០០-១១:០០

វេនរសៀល៖ ១៥:០០-១៧:០០

៣. វគ្គសិក្សាសមត្ថភាព៖ អនុវត្តនីតិវិធីសុខភាព និងសុវត្ថិភាពក្នុងអាជីព

(សិក្សារៀងរាល់ថ្ងៃពុធ ដោយមាន ២វេន ១វេន រយៈពេល ០២ ម៉ោង)

វេនព្រឹក៖ ០៩:០០-១១:០០

វេនរសៀល៖ ១៥:០០-១៧:០០

៤. វគ្គសិក្សាសមត្ថភាព៖ សម្អាតបរិវេណ និងកម្ចាត់មេរោគ

(សិក្សារៀងរាល់ថ្ងៃព្រហស្បតិ៍ ដោយមាន ២វេន ១វេន រយៈពេល ០២ ម៉ោង)

វេនព្រឹក៖ ០៩:០០-១១:០០

វេនរសៀល៖ ១៥:០០-១៧:០០

៥. វគ្គសិក្សាសមត្ថភាព៖ ក្រមប្រតិបត្តិ និងវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មទេសចរណ៍

(សិក្សារៀងរាល់ថ្ងៃសុក្រ ដោយមាន ២វេន ១វេន រយៈពេល ០២ ម៉ោង)

វេនព្រឹក៖ ០៩:០០-១១:០០

វេនរសៀល៖ ១៥:០០-១៧:០០





សម្រាប់បុគ្គលិកបម្រើការងារនៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ

ដែលមានចំណេះដឹង និងសមត្ថភាព ដែលជាក់ព័ន្ធសមត្ថភាពតម្រូវនៅក្នុងកម្មវិធីរួចហើយ

អាចធ្វើការស្នើសុំការវាយតម្លៃសមត្ថភាពអនឡាញតែម្តង

ដោយមិនចាំបាច់ចូលរៀនក្នុងវគ្គសិក្សាសមត្ថភាពនោះឡើយ។

របៀបចុះឈ្មោះ

https://www.tptd.org

**សម្គាល់៖** បុគ្គលិក-និយោជិត ដែលឆ្លងកាត់វគ្គបណ្តុះបណ្តាល និង/ឬឆ្លងកាត់ការវាយតម្លៃសមត្ថភាព និងទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដែលទទួលស្គាល់ពីក្រសួងទេសចរណ៍។